58/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ ៖ ៣៣
ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣
សាលដីកា
លេខ ៖ ៥១៨ "ក"
ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៣

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈនៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៣។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោកស្រី ជាចៅក្រម

**ក្រឡាបញ្ជី**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទ៖**លោក [redacted] ចាន់យ៉ារ៉េត (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៥០ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៥០ABEo ផ្លូវ ២៤៥ ក្រុម ២ ភូមិ ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**មេធាវី ៖** លោក [redacted] តំណាងដោយអាណត្តិ

**ចុងចោទ៖**លោក [redacted] ពៅ(ចុងបណ្តឹងសាទុក្ខ) អាយុ ៤៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះ លេខ ៦២ $E_2$ ផ្លូវ ២៤៥ ក្រុម ២ ភូមិ ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**មេធាវី ៖** លោក [redacted] តំណាងដោយអាណត្តិ

<u>**កម្មវត្ថុបណ្តឹង**</u> **៖ ប្តឹងសុំអោយគោរពកិច្ចសន្យាទិញ-លក់ផ្ទះ និង សុំទាមទារផ្ទះ។**



មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា ៤០០ Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia

Scanned with CamScanner

## <u>អំពីអង្គហេតុ និង ចំណុចវិវាទៈ</u>

**ក-<u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារៈ</u>**

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់ឈ្មោះ[redacted] ចាន់យ៉ារ៉េត ទាមទារអោយតុលាការចេញ ៖ អោយឈ្មោះ[redacted] ពៅ និង ប្រពន្ធឈ្មោះ [redacted] មុំ គោរពតាមលិខិតលក់ផ្តាច់ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ដោយអោយឈ្មោះទាំងពីរនាក់ប្តីប្រពន្ធប្រគល់ផ្ទះលេខ ៦២ $E_2$ ផ្លូវលេខ ២៤៥ ក្រុម ២ ភូមិ ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ មកអោយខ្លួនតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ (ចុះហត្ថលេខាដោយលោកអភិបាលខណ្ឌ[redacted] យុយ នៅថ្ងៃទី ១៣-០២-២០១២) និង កិច្ចសន្យាធានាអះអាងចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

តាមពាក្យបណ្តឹងតប ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២ របស់មេធាវីតំណាងអោយចុងចម្លើយទាមទារអោយតុលាការចេញដូចខាងក្រោម ៖

១-រំលាយកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ០៣-០២-២០១២ ។

២-លុបចោលលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៧០/១២ល.បអភិ ចុះថ្ងៃទី ១៣-០២-២០១២ របស់អភិបាលខណ្ឌចំការមន ។

៣-ទាមទារសំណងថ្លៃខូចខាតប្រាក់កក់ធ្វើលិខិតផ្ទេរសិទ្ធិសេវាកម្មច្បាប់ និង ចំណាយផ្សេងៗទៀតចំនួន ៤០.០០០.០០០រៀល ។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៥០ "ខ" ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ សំរេចៈ**

១-ច្រានចោលចំណុចទាមទារនៅក្នុងបណ្តឹងតប ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២ របស់មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយទាំងមូល ។

២-បង្គាប់អោយចុងចម្លើយឈ្មោះ [redacted] ពៅ និង ប្រពន្ធឈ្មោះ[redacted] មុំ ប្រគល់ផ្ទះលេខ ៦២ $E_2$ ផ្លូវលេខ ២៤៥ ក្រុម ២ ភូមិ ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ និង លិខិតពាក់ព័ន្ធផ្ទះលេខ ៦២ $E_2$ ទាំងអស់ អោយទៅភាគីដើមចោទឈ្មោះ[redacted] ចាន់យ៉ារ៉េត និង ប្រពន្ធឈ្មោះ[redacted] ស្រីមុំ ចាប់ពីថ្ងៃសាលក្រមស្ថាពរ ។

៣-បង្គាប់អោយដើមចោទឈ្មោះ[redacted] ចាន់យ៉ារ៉េត និង ប្រពន្ធឈ្មោះ[redacted] ស្រីមុំ សងប្រាក់ថ្លៃផ្ទះលេខ



Scanned with CamScanner

៦២ $E_2$ ផ្លូវលេខ ២៤៥ ក្រុម ២ ភូមិ ១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ បង្គ្រប់ចំនួន ៤៣.០០០ដុល្លា(បួនម៉ឺនបីពាន់ដុល្លារអាមេរិក) អោយទៅភាគីចុងចម្លើយឈ្មោះ [redacted] ពៅ និង ប្រពន្ធឈ្មោះ [redacted] មុំ ចាប់ពីថ្ងៃសាលក្រមស្ថាពរ។

៤-បង្គាប់អោយចុងចម្លើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី។

សាលក្រមនេះទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ចំពោះមុខមេធាវីតំណាងដោយអាណត្តិអោយដើមចោទ និង មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

*សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] ពៅ ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៣៦៣ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ គ្រង់ចំណុច នៃសេចក្តីសំរេចទាំងមូល។*

*សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] ចាន់យ៉ារ៉េត ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៣៧៨ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ គ្រង់ចំណុច នៃសេចក្តីសំរេចទាំងមូល។*

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៧ ក្រ V.ប ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍សំរេច ៖**

១-ច្រានចោលបណ្តឹងឧទ្ធរណ៍លេខ ៣៧៨ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់ភាគីដើមចោទមានមេធាវី [redacted] តំណាងដោយអាណត្តិ។

-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៦៣ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់ភាគីចុងចម្លើយមានមេធាវី [redacted] តំណាងដោយអាណត្តិទុកជាត្រឹមត្រូវតាមច្បាប់។

២-លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ៥០(ខ) ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ។

៣-បង្គាប់អោយភាគីចុងចម្លើយឈ្មោះ [redacted] ពៅ និង ប្រពន្ធឈ្មោះ [redacted] មុំ សងប្រាក់កក់ចំនួន ៥ដង (ប្រាំដង) ស្មើនឹង ១០.០០០ដុល្លា(មួយម៉ឺនដុល្លារអាមេរិក) ទៅភាគីដើមចោទឈ្មោះ [redacted] ចាន់យ៉ារ៉េត តាមលិខិតលក់ផ្តាច់ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៥-សាលដីកានេះជំនុំជំរះជាសាធារណៈ ថ្ងៃទី ២០-០២-២០១៣ និង ប្រកាសជាសាធារណៈថ្ងៃទី ២២



Scanned with CamScanner

ខែ កុម្ភៈ ឆ្នាំ ២០១៣។

បើកផ្លូវប្តឹងសាទុក្ខក្នុងរយៈពេល ០១ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

*សាលដីកានេះត្រូវបានឈ្មោះ [redacted] ចាន់យ៉ារ៉េត ប្តឹងសាទុក្ខតាមបណ្តឹងលេខ ៦៩ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ត្រង់ចំណុច នៃសេចក្តីសំរេចទាំងមូល ។*

**ខ-អំពីសេចក្តីថ្លែងការណ៍របស់គូភាគីៈ**

ឈ្មោះ [redacted] ចាន់យ៉ារ៉េត ធ្វើសេចក្តីថ្លែងការណ៍ថា ៖ ខ្លួនទាក់ទងទៅអាជ្ញាធរខ័ណ្ឌ ដើម្បីអោយឆាន់ ពៅ មកទទួលប្រាក់បង្គ្រប់ចំនួន ៤៣.០០០ដុល្លា តែឈ្មោ[redacted] ពៅ មិនព្រមផ្តិតមេដៃ ហើយពេលនោះមានអ្នកមកឆាឆៅទើបអាក់ខាន។ ខ្លួនបានសួរពត៌មានពីលោកប្រធានភូមិអំពីការរត់ការផ្ទេរសិទ្ធិ តើដល់ណាហើយ តែគាត់រកលេសម្តងថាអញ្ចេះ ម្តងថាអញ្ចុះ។ ខ្លួនព្យាយាមជួបគាត់រហូតមក តែគាត់ព្យាយាមគេចពីខ្លួន។ ខ្លួនទិញផ្ទះលើបំផុត ឯខាងក្រោមមានម្ចាស់ផ្សេង។ មុនទិញគាត់បានមកអង្វរខ្លួន ម្តាយខ្លួន និង ប្រពន្ធខ្លួនអោយទិញផ្ទះគាត់។ គូភាគីបានអនុវត្តកិច្ចសន្យាសឹងតែ ១០០% ហើយ នៅតែការប្រគល់ប្រាក់ប៉ុណ្ណោះ។

សំណូមពរ ៖ សុំផ្តល់យុត្តិធម៌អោយខ្លួនផង។

**ក្រឡាបញ្ជីអានសារណាតបរបស់ចុងចម្លើយ**

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយដើមចោទ ធ្វើសេចក្តីថ្លែងការណ៍ថា ៖ ដើមចោទ និង ប្រពន្ធជាអ្នកសរសេរលិខិតលក់ផ្តាច់ ហើយឈ្មោះ យុត អូន ជាអ្នករត់បែបបទផ្ទេរសិទ្ធិរយៈពេល១អាទិត្យ តែពេលលិខិតផ្ទេរសិទ្ធិធ្វើហើយ ចុងចម្លើយបែរជាមិនព្រមប្រគល់អោយដើមចោទ ដើម្បីទទួលប្រាក់បង្គ្រប់។ ភាគីម្ចាស់ផ្ទះបានគេចវេសមិនចង់លក់ផ្ទះអោយកូនក្តីខ្លួនវិញ ទោះជាកូនក្តីខ្លួនបានព្យាយាមជួបយ៉ាងណាក៏ដោយ ។ កូនក្តីខ្លួនមិនបានដាក់លក្ខខ័ណ្ឌទេ គឺគ្រាន់តែជាសំណូមពររបស់កូនក្តីខ្លួនប៉ុណ្ណោះ។

បើកូនក្តីខ្លួនមិនទទួលលិខិតផ្ទេរសិទ្ធិ និង ប្រគល់ប្រាក់បង្គ្រប់ ចុងចម្លើយត្រូវទាក់ទងទៅឈ្មោះ យុត អូន។ ការសំរេចរបស់សាលាឧទ្ធរណ៍បដិសេធសាលក្រមសាលាដំបូង គឺអយុត្តិធម៌ណាស់សម្រាប់កូនក្តីខ្លួន ព្រោះកូនក្តីខ្លួនចង់ទិញផ្ទះមិនមែនចង់បានប្រាក់កក់ គុណ ៥ នេះទេ។

សំណូមពរ ៖ សុំបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍វិញ

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយ ធ្វើសេចក្តីថ្លែងការណ៍ថា ៖ ប្រពន្ធកូនក្តីខ្លួនពិតជាបានធ្វើលិខិតលក់ផ្ទះអោយប្រពន្ធដើមចោទតម្លៃ ៤៥.០០០ដុល្លា ដោយបានទទួលប្រាក់កក់ ២.០០០ដុល្លា។ ក្រោយមកកូនក្តីខ្លួនបានទៅចរចារដើម្បីយកប្រាក់បង្គ្រប់ទៅទិញផ្ទះថ្មី តែត្រូវបានដើមចោទ



Scanned with CamScanner

អោយកូនក្តីខ្លួន និង មេភូមិទៅចរចារជាមួយម្ចាស់ផ្ទះខាងក្រោម អី១ , អី២ ដើម្បីសាងសង់បន្ថែម ។ កូនក្តីខ្លួន និង មេភូមិបានទៅទាក់ទងហើយ តែអ្នកខាងក្រោមមិនព្រម ទើបដើមចោទមិនព្រមប្រគល់ប្រាក់បង្គ្រប់អោយកូនក្តីខ្លួន។ ដោយកូនក្តីខ្លួនមិនចង់មានរឿងរ៉ាវ ទើបពេលនេះកូនក្តីខ្លួនសុខចិត្តទទួលយកតាមការសំរេចរបស់សាលាឧទ្ធរណ៍។

**សំណូមពរ :** សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ សារណាត្រៀមរបស់ចុងចម្លើយ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីរបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៦៩ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ របស់លោក [redacted] ចាន់យ៉ារ៉េត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចលុបចោលសាលក្រមរដ្ឋប្បវេណីលេខ ៥០(ខ) ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ និង បង្គាប់អោយភាគីចុងចម្លើយសងប្រាក់កក់ចំនួន ៥ដង ស្មើនឹង ១០.០០០ដុល្លា ទៅភាគីដើមចោទ តាមលិខិតលក់ផ្តាច់ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

ចំណុចវិវាទនៃរឿងក្តីនេះ គឺត្រូវរំលាយលិខិតលក់ផ្តាច់ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឬត្រូវបន្ត ប៉ុន្តែសាលាឧទ្ធរណ៍មិនបានសំរេចអំពីបញ្ហានេះទេ។

-យល់ឃើញថា សាលាឧទ្ធរណ៍គប្បីពិចារណាអោយបានគ្រប់ជ្រុងជ្រោយមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី ថាតើភាគីបានចាប់ផ្តើមអនុវត្ត ឬនៅ ? ។

-យល់ឃើញថា ភាគីចុងចម្លើយមិនបានមកចូលរួមសវនាការនេះទេ ប៉ុន្តែមេធាវីចុងចម្លើយបានចូលរួម តុលាការកំពូលអាចដំណើរការបាន ។



Scanned with CamScanner

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ០៧ ក្រVប ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ សំរេចសេចក្តីបកនេះ មិនត្រឹមត្រូវតាមនីតិច្បាប់ ។

## ហេតុដូចនេះ

## ស ម្រេ ច

១-ទទួលបណ្តឹងសាទុក្ខលេខ ៦៥ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] ចាន់យ៉ារ៉េត ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ០៧ ក្រVប ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣ ចុះថ្ងៃទី ០១ ខែ មេសា·ឆ្នាំ ២០១៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះសាជាថ្មីឡើងវិញ ។

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់ចុងចម្លើយ ។

៥-សាលដីកានេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសជាសាធារណៈ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៣ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ចៅក្រម |
| លោក | | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣

ប្រធាន

[redacted]